# អ្វីទៅជាសំណុំរឿង០០២/០១?

*ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២*
*លីម ជ័យច័ត្ត, អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម*
*មជ្ឈមណ្ឌលឯកសារកម្ពុជា*

*នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយដោយធ្វើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ឲ្យទៅជាផ្នែកតូចៗ ដែលអនុញ្ញាតឲ្យខ្លួនអាចជ្រើសរើសយកអង្គហេតុ ឬបទចោទប្រកាន់ ត្រង់ផ្នែកណាមួយក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីយកមកបើកសវនាការ ។ ផ្នែកដំបូងដែលអង្គជំនុំជម្រះយកមកបើកសវនាការនោះត្រូវបានកំណត់ថាជាសំណុំរឿង០០២/០១ (អានថា សូន្យសូន្យពីរស្លាស់សូន្យមួយ) ។ ក្នុងសំណុំរឿង០០២/០១ នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើកយកការចោទប្រកាន់លើអង្គហេតុមួយចំនួនដើម្បីបើកសវនាការ ។ ការចោទប្រកាន់លើអង្គហេតុទាំងនោះរួមមាន៖*

*ក) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ។*

*ខ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់បានទទួលការចាត់តាំងនូវតួនាទីទាំងនោះ ។*

*គ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេតាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការតាមពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*ឃ) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។*

*ង) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ។*

*ច) ការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិ៍ជ្រៃ ។*

*សូមបញ្ជាក់ថា ការចោទប្រកាន់លើអង្គហេតុទាក់ទងនឹងការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិ៍ជ្រៃ គឺទើបតែត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ថ្មីៗនេះ បន្ទាប់ពីមានសំណើរបស់សហ-*

ព្រះរាជអាជ្ញាស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើសំណុំរឿង ០០២/០១ ។

នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងនឹងលើកយក បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ មកធ្វើការវិនិច្ឆ័យ ។ រីឯ បទចោទទាក់ទងនឹងបទប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ត្រូវបានទុកមួយអន្លើសម្រាប់ដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី ។

នៅក្នុងសវនាការលើសំណុំរឿង០០២/០១ ចំនួន សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវកម្រិតត្រឹមតែបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះយល់ឃើញថា មានជាប់ពាក់ព័ន្ធនឹងអង្គហេតុនៅដំណាក់កាលដំបូងនេះតែប៉ុណ្ណោះ ។

សូមបញ្ជាក់ថា រហូតមកដល់ពេលនេះ អង្គជំនុំជម្រះបាននឹងកំពុងបើកសវនាការជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហានលន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិ៍ជ្រៃ ។ ចំពោះអង្គហេតុផ្សេងៗទៀត អង្គជំនុំជម្រះបញ្ចប់ការស្តាប់សក្ខីកម្ម សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរួចស្រេចហើយ...

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជំនុំជម្រះក្តីលើសំណុំរឿង០០២/០១រួចរាល់ អង្គជំនុំជម្រះនឹងចេញសាលក្រមសម្រេចលើការចោទប្រកាន់ដូចបានរៀបរាប់ខាងលើ ដោយផ្តន្ទាទោសសមស្របមួយ ប្រសិនបើអង្គជំនុំជម្រះរកឃើញថាជនជាប់ចោទពិតជាមានពិរុទ្ធភាពមែន ។

-ចប់-